ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ៣៨០៣
ចុះថ្ងៃទី១៩-០៧-២០១៦
ជំនុំជម្រះលេខ ៣០០៦
ចុះថ្ងៃទី០២-០៩-២០១៦
សាលក្រមលេខ
លេខៈ ៥៦៨ ក្រ៧៖
ចុះថ្ងៃទី២៧-១២-២០១៦

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅសាលាជំនុំជម្រះក្តី នៃសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៦ វេលាម៉ោង ៨ព្រឹក ដោយមានសមាសភាពជំនុំជម្រះដូចតទៅ ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោក [redacted] ធាសនា ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សា
-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា
-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៨០៣ ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៦ ដែលមានជនជាប់ចោទ៖

-ឈ្មោះ [redacted] សុធា ហៅវិត ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ មុខរបរ ជាងដែក ទីកន្លែងកំណើតនៅភូមិជំរៅ ស្រុកព្រះស្តេច ខេត្តព្រៃវែង មានទីលំនៅមុនពេលចាប់ខ្លួនស្នាក់នៅផ្ទះជួល ភូមិទួលពង្រ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] រស់ ម្តាយឈ្មោះ [redacted] រស់ ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០២នាក់ ទោសពីមុនគ្មាន ជានិតិជន។

-ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំលេខ ៨៣៥៣ ណ ដ.ឃ.ដ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦

ពីបទ **រំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅចំណុចបន្ទប់លេខ ៦៦ ក្នុងភោជនីយដ្ឋាន និងខារ៉ាអូខេ យ៉ីយោ រាជនី ផ្លូវលេខ២០០៨ ភូមិត្រពាំងល្វា សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាម ២៣៩ នៃក្រមព្រហ្មទណ្ឌ។

-លោក [redacted] **សុខដេង** ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

-ជនរងគ្រោះឈ្មោះ [redacted] សុភ័ត្រ ភេទស្រី អាយុ ១៨ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នស្នាក់នៅក្នុងការ៉ាអូខេ យ៉ីយោរាជនី ផ្លូវ២០០៨ ស្ថិតនៅភូមិត្រពាំងល្វា សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ៕

Scanned by CamScanner

**អង្គហេតុនៃរឿងមានដូចតទៅ:**

-កាលពីថ្ងៃទី១៤ ខែ កក្កដា ឆ្នាំ ២០១៦ វេលាម៉ោងប្រហែល ០១ និង ៤០នាទី ឈ្មោះ [redacted] សុធា បានទៅច្រៀងការ៉ាអូខេនៅបន្ទប់លេខ ៦៦៦ ក្នុងភោជនីដ្ឋាន និងខារ៉ាអូខេយ៉ីហោ រាជនី ផ្លូវ ២០០៤ ស្ថិតនៅភូមិត្រពាំងល្វា សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ ពេលទៅដល់ឈ្មោះ [redacted] សុធា និងឈ្មោះ វិចិត្រ បានកម្មង់ស្រាបៀចំនួនមួយកេះ ហើយឈ្មោះ [redacted] សុភ័ត្រ្ត មកអង្គុយផឹកកំដរ រីឯឈ្មោះ វិចិត្រ ក៏បានហៅមេការឈ្មោះ [redacted]វណ្ណី មកអង្គុយផឹកកំដរដែរ។ លុះដល់ម៉ោង ០១ និង ៥០នាទីយប់ ឈ្មោះ វិចិត្រ ស្រវឹងស្រាខ្លាំងក៏ដេកលក់លើសាឡុង រីឯឈ្មោះ វីវណ្ណី ក៏ដើរចេញក្រៅបន្ទប់ខារ៉ាអូខេ ស្រាប់តែឈ្មោះ [redacted] សុធា បានធ្វើសម្មភាពចាប់អោបថើបឈ្មោះ [redacted] សុភ័ត្រ្ត និងបានលូកដៃចូលទៅក្នុងអាវហើយប្របាច់ដោះឈ្មោះ [redacted] សុភ័ត្រ្ត រួចឈ្មោះ [redacted] សុធា ក៏រូតខោខៅបិយ ហើយយកប្រដាប់ភេទដាក់បញ្ចូលទៅក្នុងប្រដាប់ភេទរបស់ ឈ្មោះ [redacted] សុភ័ត្រ្ត ពេលនោះឈ្មោះ [redacted] សុភ័ត្រ្ត បានស្រែកហៅឲ្យមេការឈ្មោះ [redacted]វណ្ណី ជួយ ស្រាប់តែឈ្មោះ [redacted] សុធា បានវាយទៅលើឈ្មោះ [redacted] សុភ័ត្រ្ត ត្រូវចំពោះមួយដៃបណ្ដាលឲ្យចុក ស្រែកលែងរួចភ្លាមនោះឈ្មោះ [redacted]វណ្ណី បានចូលមកកាន់ ទើបឈ្មោះ [redacted] សុធា ស្ទុះងើបឡើងលើកខោបំរុងគេចខ្លួន តែម្ចាស់ហាងខារ៉ាអូខេខាងលើចាប់ឃាត់ខ្លួនប្រគល់ឲ្យសមត្ថកិច្ចតែម្តង។

-បានឃើញ របាយការណ៍សំយោគលេខ ១៨៩/០១៦ របក ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៦ របស់អធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ១៩៣២ អ.យ.ឧ ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៦ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ២២៨៦ អ.យ.ឧ ចុះថ្ងៃទី២៤-០៨-២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ២៩៤៨ ដ.ជ. ចុះថ្ងៃទី២៦-០៨-២០១៦ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។

<u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ [redacted]សុធា បានឆ្លើយនាពេលសវនាការណ៍ថា: កាលពីថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០១៦ វេលាម៉ោង ០៨ជាងយប់ ខ្ញុំបានចេញពីផ្ទះបងប្អូនរបស់មេខ្ញុំឈ្មោះ វិចិត្រ នៅជិតផ្សារឈូកមាស ទៅច្រៀងការ៉ាអូខេនៅហាងយ៉ីហោរាជនី នៅផ្លូវម៉ែដា សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ជាមួយឈ្មោះ វិចិត្រ។ ពេលទៅដល់ខ្ញុំជាមួយមេជាង បានហៅស្រាបៀផឹកមួយកេះ និងហៅស្រីមកអង្គុយកំដរ ០២នាក់ ជាមួយមេការស្រីនាក់ ពេលផឹកបានប្រហែល ០១ ម៉ោងពូកខ្ញុំក៏គិតប្រាក់ចេញមកវិញ ជិះម៉ូតូចេញមកដល់ចំណុចថ្លឹងឡានផ្លូវម៉ែដា ស្រាប់តែមេជាងរបស់ខ្ញុំឈ្មោះ វិចិត្រ បបួលខ្ញុំចូលច្រៀងខារ៉ាអូខេនៅហាងដដែលមួយម៉ោងទៀត ខ្ញុំក៏យល់ព្រមហើយ ត្រឡប់ទៅច្រៀងបន្តទៀត។ ពេលចូលច្រៀងបានប្រហែលកន្លះម៉ោង ខ្ញុំក៏បានអោបថើបនារីអង្គុយកំដរ ហើយពេលខ្ញុំដើរចូលទៅក្នុងបន្ទប់ទឹកខ្ញុំជំពុបជើងដួលទៅលើនារីម្នាក់នោះ ហើយខ្ញុំក៏បានសួរថា: ស្រឡាញ់ខ្ញុំអត់ ហើយនារីម្នាក់នោះញញឹម បន្ទាប់មកខ្ញុំក៏ធ្វើសកម្មភាពចាប់អោប និងចាប់ស្រាតខោក្រៅ និងខោក្នុងនារីម្នាក់នោះចេញហើយរូតខ្សែរូតខោរបស់ខ្ញុំ យកប្រដាប់ភេទរបស់ខ្ញុំដាក់បញ្ចូលចូល ក្នុងប្រដាប់ភេទនារីម្នាក់នោះ ហើយនារីនោះក៏ស្រែកហៅមេកាខារ៉ាអូខេឲ្យជួយនាង ពេលនោះមេការការ៉ាអូខេបានចូលមកក្នុងបន្ទប់ ហើយធាក់ខ្ញុំខ្ទាត់ទៅជញ្ជាំង ហើយខ្ញុំក៏បានដើរចេញមកក្រៅខារ៉ាអូខេ បន្ទាប់មកខ្ញុំក៏ដើរចូលទៅវិញ ដើម្បីហៅមេជាងរបស់ខ្ញុំដែលស្រវឹងអង្គុយក្នុងបន្ទប់ខារ៉ាអូខេ ស្រាប់តែមានមនុស្សប្រុសដែលធ្វើការនៅក្នុងហាងខារ៉ាអូខេបានមកព្រួតគ្នាវ៉ៃខ្ញុំដល់សន្លប់ ហើយហៅសមត្ថកិច្ចមកចាប់ឃាត់ខ្លួនខ្ញុំបាទតែម្តង៕

Scanned by CamScanner

-តាមអំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] សុភ័ក្រ្ត បានឆ្លើយបញ្ជាក់នៅសត្ថកិច្ចថាៈ នៅមុនពេលកើតហេតុ វេលាម៉ោងជា ២២ និង ៣០នាទី ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៦ ខ្ញុំកំពុងអង្គុយចាំទទួលភ្ញៀវខារ៉ាអូខេ នៅក្នុងហាងខារ៉ាអូខេ រាជនី ហើយពេលនោះមេការឈ្មោះ[redacted]ណ្ណី ភេទស្រី អាយុ ២៣ឆ្នាំ បានហៅពួកខ្ញុំជានារីខារ៉ាអូខេទៅទទួលភ្ញៀវបន្ទប់លេខ៦ ពេលនោះជនសង្ស័យឈ្មោះ[redacted]សុធា បានអោយនាងអង្គុយជាមួយ ហើយពួកគេក៏បានហៅស្រាបៀរអង្គុយផឹកអស់មួយកេះ ពេលគេផឹកអស់ហើយគេក៏គិតលុយចេញទៅបាត់ទៅ។ លុះបានប្រហែលជា ២០នាទីភ្ញៀវទាំងពីនាក់ក៏ត្រឡប់មកវិញដោយហៅស្រាបៀមួយឈុតទៀត (មួយកេះ) ហើយហៅខ្ញុំជាមួយមេការឈ្មោះ[redacted]ណ្ណី ចូលដដែល រហូតដល់ម៉ោងប្រហែល ០១ និង ៤០នាទីឈានចូលថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦ ជនសង្ស័យឈ្មោះ [redacted] សុធា "រឺត" បានធ្វើសកម្មភាពមកអោបថើបខ្ញុំរីឯមិត្តភ័ក្រ្តគេម្នាក់ដែលចូលជាមួយ ដេកស្រវឹងមិនដឹងខ្លួននៅលើលាឡុង ហើយពេលនោះមេការគាត់បានចេញទៅក្រៅបន្ទប់ទៀត ស្រាប់តែពេលនោះជនសង្ស័យឈ្មោះ [redacted] សុធា បានធ្វើសកម្មភាពចាប់ច្របាច់ដោះ ហើយចាប់ផ្តួលខ្ញុំទៅលើឥដ្ឋការ៉ូ រួចស្រាតខោខៅប៊ូយជើងខ្លី និងស្រាតខោលីអូដល់ចុងជើង ហើយខ្ញុំខំប្រឹងរើបំរាស់ ស្រែកអោយមេការជួយ ស្រាប់តែឈ្មោះ [redacted] សុធា បានវ៉ៃពោះខ្ញុំមួយដៃ ថាកុំឲ្យស្រែក បន្ទាប់មកឈ្មោះ [redacted]ុធា បានរូតខោគេ ហើយយកក្តៅ (លឹង្គ) ដាក់មកដាក់ចូលក្នុងប្រដាប់ភេទខ្ញុំ ហើយរុកចុះរុកឡើងប្រហែលជិតប្រាំនាទី ស្រាប់តែពេលនោះមេការស្រីបានមកទាន់ ធាក់ជនសង្ស័យចេញហើយ ខ្ញុំរត់ចូលក្នុងបន្ទប់ទឹក ដោយឈាមប្រលាក់ជាប់ខោក្នុង ហើយជនសង្ស័យរត់គេចខ្លួន ក៏ត្រូវអ្នកធ្វើការក្នុងខារ៉ាអូខេឃាត់ខ្លួនប្រគល់ឲ្យសមត្ថកិច្ច។

-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted]វណ្ណី បានឆ្លើយនៅសមត្ថកិច្ចថាៈ នៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៦ វេលាម៉ោងប្រហែល ២០ ខ្ញុំកំពុងនៅក្នុងខារ៉ាអូខេ រាជនី ផ្លូវ២០០៤ ភូមិត្រពាំងល្វា សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ពេលនោះក៏ឃើញភ្ញៀវពីរនាក់ ដើរចូលមករកបន្ទប់ខារ៉ាអូខេច្រៀង ខ្ញុំបាននាំចូលទៅក្នុងបន្ទប់លេខ៦៦៦ ហើយពួកគេបានកម្ម៉ង់ស្រាបៀរអង្គរមួយឈុន និងមានស្រីកំដរពីនាក់គឺរូបខ្ញុំ និងឈ្មោ[redacted] សុភ័ក្រ្ត (ជនរងគ្រោះ) ពួកអ្នកទាំងពីរនាក់ផឹកអស់រយៈពេល ២ម៉ោង នៅសល់ស្រាបៀរពីរកំប៉ុងចំនួន ០៣កំប៉ុង ហើយបានគិតលុយចេញទៅវិញ។ លុះដល់ម៉ោងប្រហែល២៣ ភ្ញៀវទាំងពីរនាក់នោះបានត្រឡប់មកច្រៀងម្តងទៀត ហើយចូលក្នុងបន្ទប់ដដែល និងបានកម្មង់ស្រាបៀរដដែល ហើយពួកខ្ញុំក៏អង្គុយជាមួយភ្ញៀងនោះទៀត ពេលផឹកច្រៀងបានប្រហែលជាងមួយម៉ោង ស្រាប់តែភ្ញៀវម្នាក់ដែលអង្គុយជាមួយខ្ញុំដេកលក់លើសាឡុង ចំណែកភ្ញៀវម្នាក់ទៀតនៅអង្គុយជ្រុងម្ខាងជាមួយឈ្មោះសុភ័ក្រ្ត បន្តិចក្រោយមកខ្ញុំ ឃើញក៏ដេកដែរ គាប់ជួនពេលនោះមានមេការបានហៅខ្ញុំតាមរយៈភូបអោយ ចុះក្រោមជួយគិត លុយ ពេលលឺដូចនេះខ្ញុំក៏ចុះទៅក្រោម ពេលខ្ញុំចុះទៅក្រោមបានប្រហែល ដប់នាទីក៏ឡើងមកវិញ ខ្ញុំក៏បើកបន្ទប់ស្រាប់តែឃើញភ្ញៀវម្នាក់អង្គុយជាមួយឈ្មោះ[redacted]ុភ័ក្រ្ត នោះបានក្រាបពីលើឈ្មោះ [redacted]សុភ័ក្រ្ត នៅលើកំរាលឥដ្ឋមុខបន្ទប់ទឹកដោយគ្មានស្លៀកខោទេ មានតែអាវ ហើយយំពេលឃើញ ដូចនេះ ខ្ញុំចូលទៅតាមឈ្មោះ[redacted] សុភ័ក្រ្ត ហើយសួរនាំចំណែកភ្ញៀវនោះរត់គេចទៅក្រៅខ្ញុំក៏អោយអ្នកធ្វើការនៅក្នុងហាងជាមួយឃាត់ភ្ញៀវនោះបាន ហើយបានរាយការណ៍ជូនសមត្ថកិច្ចតែម្តង

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានៈ ក្រោយពីបានសួរដេញដោលជនជាប់ចោទនាពេលសវនាការ ក៏ដូចជាបានស្តាប់ក្រឡាបញ្ជីអានអំណានចម្លើយរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរួចមកឃើញថាៈ ចម្លើយសារភាពរបស់ជនជាប់ចោទ មានលក្ខណៈស៊ីសង្វាក់ទៅនឹងរបាយការណ៍របស់សមត្ថកិច្ច និងមានពិរុទ្ធភាពគ្រប់គ្រាន់ពីបទ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅចំណុចបន្ទប់លេខ ៦៦៦ ក្នុងភោជនីដ្ឋាន និងខារ៉ាអូខេយ៉ហោ រាជនី ផ្លូវលេខ២០០៤ ភូមិត្រពាំងល្វា សង្កាត់កាកា

Scanned by CamScanner

ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៦ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ដូចនេះតំណាងអយ្យការសុំតម្កល់ការចោទតាមដីកាសន្និដ្ឋានស្ថាពរលេខ ២២៨៦ អ.យ.ឌ ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ ទុកជាបានការទាំងមូល និងសុំឲ្យលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះសម្រេចតាមច្បាប់។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋាននាពេលសវនាការថា៖ ក្រោយពីបានសួរដេញដោលនាពេលសវនាការរួចមកឃើញថា: កូនក្តីរបស់ខ្លួនបានឆ្លើយសារភាពរួចហើយថាខ្លួនពិតជាបានប្រព្រឹត្តអំពើ រំលោភសេពសន្ថវៈ ពិតប្រាកដមែន។ ហេតុដែលកូនក្តីរបស់ខ្លួនប្រព្រឹត្តនោះដោយសារតែខ្លួនស្រវឹង និងយល់ថាជនរងគ្រោះបានព្រៀមព្រៀងជាមួយគាត់។ ដូចនេះក្នុងនាមខ្លួន ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទស្នើសុំលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះបន្ធូបន្ថយទោសឲ្យកូនក្តីខ្លួនផង។

សម្តីចុងក្រោយរបស់ជនជាប់ចោទ ស្នើសុំឲ្យតុលាការជួយបន្ធូបន្ថយទោសឲ្យខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted]សុធា ហៅរិត។

-ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]សុភ័ក្ត្រា។

-ក្រោយពីបានស្តាប់អំណានចម្លើយសាក្សីឈ្មោះ [redacted]វណ្ណី។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ភស្តុតាង ឯកសារនានា

-ក្រោយពីបានចរណាត្រឹមត្រូវតាមច្បាប់ហើយ

<u>សំអាងហេតុ</u>

១-តុលាការបានទទួលជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៨០៣ ចុះថ្ងៃទី ១៩ ខែ កក្កដា ២០១៦ តាមរយៈដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ២៩៨៨ "ណ" ដ.ជ. ចុះថ្ងៃទី២៦-០៨-២០១៦ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ដែលបានចោទប្រកាន់លើៈឈ្មោះ[redacted] សុធា "ហៅរិត" ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ ពីបទ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅចំណុចបន្ទប់លេខ៦៦៦ ក្នុងភោជនីដ្ឋាន និងខារ៉ាអូខេយីហោ រាជនី ផ្លូវលេខ២០០៤ ភូមិត្រពាំងល្វា សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៦ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។

២-របាយការណ៍សំយោគលេខ ១៩៩/១៦ រ.ប.ក ចុះថ្ងៃទី១៨ ខែ កក្កដា ឆ្នាំ ២០១៦ របស់អធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានសន្និដ្ឋានថា: ឈ្មោះ [redacted] សុធា ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ ពិតជាបានប្រព្រឹត្តអំពើ រំលោភសេពសន្ថវៈ នៅចំណុចក្នុងបន្ទប់ការ៉ាអូខេលេខ៦៦៦ ភោជនីដ្ឋាន យីហោ រាជនី ផ្លូវ២០០៤ ភូមិត្រពាំងល្វា សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ពិតប្រាកដមែន។

៣-ជនជាប់ចោទឈ្មោះ [redacted] សុធា បានឆ្លើយសារភាពថា: កាលពីថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៦ ខ្លួនពិតជាបានធ្វើសកម្មភាពចាប់រំលោភជនរងគ្រោះឈ្មោះ[redacted]សុភ័ក្ត្រា ប្រព្រឹត្តនៅចំណុចបន្ទប់លេខ៦៦៦ ក្នុងភោជនីដ្ឋាន និងខារ៉ាអូខេយីហោរាជនី ផ្លូវលេខ២០០៤ ភូមិត្រពាំងល្វា សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ពិតប្រាកដកមែន។

៤-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]សុភ័ក្ត្រា បានឆ្លើយបញ្ជាក់នៅសមត្ថកិច្ចថា:នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៦ ជនជាប់ចោទឈ្មោះ[redacted] សុធា និងមិត្តភ័ក្តរបស់គេ បានមកអង្គុយផឹកនៅក្នុងការ៉ាអូខេ យីហោ រាជនី បន្ទប់លេខ៦៦៦ ដោយឈ្មោះ [redacted] សុធា អង្គុយជាមួយខ្លួន ចំណែកមិត្តភ័ក្ត

Scanned by CamScanner

របស់គេ អង្គុយជាមួយឈ្មោ[redacted]ណ្ណី ពួកអ្នកទាំងពីរផឹកអស់ស្រាបៀរចំនួនមួយកេះក៏គិតលុយចេញទៅ។ លុះបានប្រហែលជា ២០នាទី ក្រោយមកឈ្មោ[redacted]សុធា និងមិត្តភ័ក្តគេបានត្រឡប់មកម្តងទៀត ហៅស្រាបៀរមួយឈុតទៀត(មួយកេះ) ខ្លួន និងឈ្មោះ[redacted]ណ្ណី ក៏ចូលអង្គុយជាមួយ ហើយផឹករហូតដល់ម៉ោង ១ និង ៤០នាទី ឈានចូលថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦ ជនសង្ស័យឈ្មោះ[redacted] សុធា បានធ្វើសកម្មភាពអោបថើប[redacted]ខ្លួន ហើយចាប់ផ្តើមផ្តួលទៅលើឥដ្ឋការ៉ូ រួចស្រាតខោខៅបិយជើងខ្លី និងស្រាតខោលើអូខ្លួន (ខោក្នុង) ដល់ចុងជើង បន្ទាប់មកឈ្មោ[redacted]សុធា បានរូតខោខៅបិយ[redacted] ដាក់ចូលដាក់ចូលក្នុងប្រដាប់ភេទខ្ញុំចុះឡើងប្រហែលជាជិត ៥នាទី ពេលនោះមេការស្រីបានមកធាក់ហើយឈ្មោះ[redacted]សុធា បន្ទាប់មកឈ្មោ[redacted]សុធា បានរត់គេមកក្រៅក៏ត្រូវអ្នកធ្វើការនៅទីនោះចាប់ប្រគល់ឲ្យសមត្ថកិច្ចតែម្តង។

៥-សាក្សីឈ្មោ[redacted]ណ្ណី បានឆ្លើយបញ្ជាក់នៅសមត្ថកិច្ចថា: នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ២០ និង០០នាទី ពិតជាមានករណី រំលោភសេពស្គវ: បង្កឡើងដោយជនសង្ស័យឈ្មោ[redacted] សុធា "ហៅរិត" បានធ្វើសកម្មភាពចាប់រំលោភជនរងគ្រោះឈ្មោះ [redacted]សុភ័ក្រ្ត នៅចំណុចបន្ទប់លេខ៦៦៦ ក្នុងភោជនីដ្ឋាន និងខារ៉ាអូខេឃីហោរាជនី ផ្លូវលេខ២០០៤ ភូមិត្រពាំងល្វា សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ពិតប្រាកដមែន។

៦-នៅពេលឃាត់ខ្លួនសមត្ថកិច្ចបានដកហូតបាននូវ: ខោទ្រនាប់(លីអូ) ប្រឡាក់ឈាមចំនួនមួយ ដូចមាននៅក្នុងកំណត់ហេតុ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០១៦ របស់ប៉ុស្តិ៍នគរបាលកាកាប។

៧-តាមចម្លើយសារភាពរបស់ជនជាប់ចោទ និងចម្លើយសាក្សី ព្រមទាំងរបាយការណ៍របស់មន្រ្តីនគរបាលយុត្តិធម៌ ឃើញថា:មានលក្ខណ:ស៊ីសង្វាក់បញ្ជាក់បានថា: ជនជាប់ចោទឈ្មោះ [redacted] សុធា "ហៅរិត" ពិតជាបានប្រព្រឹត្តអំពើរំលោភសេពស្គវ: កាលពីថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៦ ប្រាកដមែន។

៨-សកម្មភាពរបស់ជនជាប់ចោទ ដែលធ្វើសកម្មភាពបញ្ចូលអង្គជាតរបស់ខ្លួនទៅលើជនរងគ្រោះដោយការប្រើហិង្សា ត្រូវបានច្បាប់កំណត់ថា: ជាបទល្មើស រំលោភសេពសន្ថវ: ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ទៅ ១០ (ដប់) តាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។

៩-អំពើរបស់ជនជាប់ចោទធ្វើឲ្យប៉ះពាល់ដល់ទំនៀមទំលាប់ប្រពៃណី កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់អ្នកដទៃ និងសណ្តាប់ធ្នាប់សាធារណ: របៀបរៀបរយសីលធម៌សង្គម ដែលច្បាប់ហាមឃាត់ ជាពិសេសបានបំពានទៅនឹងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។

១០-ជនជាប់ចោទជានីតិជន និងជាជនដែលមានស្មារតីគ្រប់គ្រាន់ ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត។

១១-ការលើកឡើងរបស់តំណាងអយ្យការក្នុងសេចក្តីសន្និដ្ឋាននាពេលសវនាការ ដោយលើកឡើងពីភស្តុតាងនានាបញ្ជាក់អំពីពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ[redacted]សុធា ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ ហើយសុំតម្កល់ការចោទប្រកាន់នោះមានលក្ខណ:ត្រឹមត្រូវតាមច្បាប់។

១២-ការលើកឡើងរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ក្នុងសេចក្តីសន្និដ្ឋាននាពេលសវនាការ សុំឲ្យតុលាការជួយបន្ធូរបន្ថយទោសឲ្យកូនក្តីខ្លួនឈ្មោះ[redacted]សុធា គប្បីតុលាការយកមកពិចារណា។

១៣-មានបន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុធា ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ ពីបទ រំលោភសេពសន្ថវ: ប្រព្រឹត្តនៅចំណុចបន្ទប់លេខ៦៦៦ ក្នុងភោជនីដ្ឋាន និងខារ៉ាអូខេឃីហោរាជនី ផ្លូវលេខ២០០៤ ភូមិត្រពាំងល្វា សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០១៦ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ។

១៤-វត្ថុចាប់យកដូចមាននៅក្នុងកំណត់ហេតុរបស់ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦ របស់ប៉ុស្តិ៍នគរបាលកាកាប ត្រូវរឹបអូសតាមមាត្រា ៦២ , ៦៣ នៃក្រមព្រហ្មទណ្ឌ។

Scanned by CamScanner

១៥-ជនរងគ្រោះបានចូលខ្លួនមកឆ្លើយបំភ្លឺនៅចំពោះមុខសមត្ថកិច្ច សុំទាមទារសំណងជំងឺចិត្ត ចំនួន ៨០០០ ដុល្លាអាមេរិក តម្បីតុលាការលើកយកមកពិចារណា និងសម្រេច។

**ហេតុដូច្នេះសម្រេច**

១-ផ្តន្ទាទោសជនជាប់ចោទៈឈ្មោះ [redacted] សុធា "ហៅរិត" ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៥ (ប្រាំ) ឆ្នាំ។

ពីបទ **រំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅចំណុចបន្ទប់លេខ ៦៦៦ ក្នុងភោជនីយដ្ឋាន និងខារ៉ាអូខេ យីយោរាជនី ផ្លូវលេខ២០០៤ ភូមិត្រពាំងល្វា សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាម ២៣៩ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] សុធា "ហៅរិត" សងសំណងជំងឺចិត្តចំនួន ៤.០០០.០០០៛ (បួនលាន) រៀល ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភ័ក្រ្ត ការទាមទារលើពីនេះច្រានចោល។

៣-វត្ថុតាងត្រូវរឹបអូសតាមមាត្រា ៦២,៦៣ គឺខោទ្រនាប់ (លីអូ) ប្រឡាក់ឈាមចំនួនមួយ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី០៩-១២-២០១៦ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៧-១២-២០១៦ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] | [redacted] | [redacted] |

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែធ្នូឆ្នាំ២០១៦
ក្រឡាបញ្ជី
[redacted]

Scanned by CamScanner